ពិនិត្យOK?

ប្រាក់បៀវត្សអប្បបរមា

ទាំងអ្នកធ្វើការងារ
ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ
កុំភ្លេច

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមា នៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

ខេត្តអូសាកា យូ ប្រាក់បៀវត្សអប្បបរមា

ចាប់ពីថ្ងៃទី 1 ខែតុលា ឆ្នាំ2026 នេះតទៅ
ចំនួនទឹកប្រាក់ក្នុងមួយម៉ោង

1,231 យ៉ែន

ធៀបនឹងឆ្នាំមុន UP 54 យ៉ែន

ទាំងអ្នកដែលប្រាក់ខែតាមខែ ទាំងអ្នកដែលប្រាក់ខែតាមថ្ងៃ តស់សាកគណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងមើល

カンボジア語版

ក្រសួងសុខាភិបាល ការងារនិងសុខុមាលភាព

របៀបគណនា សូមមើលផ្នែកខាងក្រោយ!

តស់គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងហើយប្រៀបធៀបនឹងប្រាក់បៀវត្សអប្បបរមា!

"ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា" ត្រូវអនុវត្តចំពោះអ្នកធ្វើការងារទាំងអស់
ទោះបីមានអាយុ ឬរបៀបធ្វើការខុសគ្នាដូចជា ការងារមិនពេញម៉ោង
ឬសិស្សនិស្សិតជាដើមក៏ដោយ។ សូមបំពេញប្រាក់បៀវត្សដែលចង់ឆែក(*1)
និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តនៃកន្លែងធ្វើការ
ចូលតារាងប្រៀបធៀប រួចប្រៀបធៀបវា!(*2)

វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក
និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

A អ្នកដែលមានប្រាក់ខែតាមម៉ោង

ប្រាក់ខែតាមម៉ោង		ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)
យ៉ែន	≥	យ៉ែន

B អ្នកដែលមានប្រាក់ខែតាមថ្ងៃ

ប្រាក់ខែតាមថ្ងៃ		ចំនួនមធ្យមនៃម៉ោងធ្វើការក្នុងមួយថ្ងៃដែលកំណត់		ចំនួនទឹកប្រាក់ក្នុងមួយម៉ោង		ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)
យ៉ែន	÷	ម៉ោង	=	យ៉ែន	≥	យ៉ែន

C អ្នកដែលមានប្រាក់ខែតាមខែ

ប្រាក់ខែតាមខែ		ចំនួនជាមធ្យមនៃម៉ោងធ្វើការក្នុងមួយខែដែលកំណត់		ចំនួនទឹកប្រាក់ក្នុងមួយម៉ោង		ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)
យ៉ែន	÷	ម៉ោង	=	យ៉ែន	≥	យ៉ែន

D អ្នកដែលរួមបញ្ចូលគ្នាចំណុច A B និង C ខាងលើ

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមនៅលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

① ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា B
② ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា C
③ ចំនួនទឹកប្រាក់សរុបដែលបូក ① និង ② ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖
① ប្រាក់បៀវត្សដែលទូទាត់បណ្តោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើស១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ
(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធភាពស្មាដៃ សូមទាក់ទងមកមន្ទីរការងារឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត

業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុត
ត្រឹម 600 ម៉ឺនយ៉ែន

លោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

តោះនាំគ្នាប្រើ "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ដែលគាំទ្រការដំឡើងប្រាក់បៀវត្ស!

អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ?

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ជំនួយដល់សហគ្រាសតូចនិងមធ្យម
និងប្រតិបត្តិករអាជីវកម្មខ្នាតតូចដែលមានគោលដៅវិនិយោគលើបរិក្ខារដែលរួមចំណែកដល់ការបង្កើនផលិតភាព ហើយនឹងគ្នានេះដំឡើង
"ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម (ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)"។
ក្នុងករណីដែលបានធ្វើការវិនិយោគលើបរិក្ខារជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ។

មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរស័ព្ទ អំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច
0120-366-440

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)
業務改善助成金 検索

លក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យចម្បងៗ

- ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម គឺទាបជាងប្រាក់បៀវត្សអប្បបរមាតាមតំបន់សម្រាប់ឆ្នាំសារពើពន្ធ2026
- ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
- ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
- ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
- គ្មានមូលហេតុនៃការមិនផ្តល់ការឧបត្ថម្ភដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម

ជំហានរហូតដល់ការផ្តល់ប្រាក់ឧបត្ថម្ភ

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភ និងផែនការអនុវត្តគម្រោងជាដើម ទៅមន្ទីរការងារនៃរាជធានីខេត្ត ដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ
2. ត្រួតពិនិត្យ ក្រោយសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានដាក់ពាក្យមក
3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្ត និងពាក្យស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភ ទៅមន្ទីរការងារ
4. ត្រួតពិនិត្យ ផ្តល់ឲ្យ

ឆែកតាម WEB!

វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បបរមា (មានតែភាសាជប៉ុន)
最低賃金　特設サイト　検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា សូមទាក់ទងមកមន្ទីរការងារខេត្តអូសាកា ឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត។
大阪労働局　検索

វេបសាយពិសេសអំពីការដំឡើងប្រាក់ឈ្នួល (មានតែភាសាជប៉ុន)
មានផ្សព្វផ្សាយអំពីគោលនយោបាយគាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។
賃金引上げ特設ページ　検索

ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ
អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស
សូមប្រឹក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។
ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)　働き方改革推進支援センター　検索

មូលនិធិគាំទ្រកំណែទម្រង់របៀបធ្វើការ
សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្តល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការ
ទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។
ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)　働き方改革推進支援資金　検索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。
(R8.9)